**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើក
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៣
## នៅអគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី
## ថ្ងៃព្រហស្បតិ៍ ១២ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣

- សូមគោរពអង្គពិធីទាំងមូល
- ឯកឧត្តម លោកជំទាវ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត កាកបាទក្រហមកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!

ʼ ថ្ងៃនេះខ្ញុំពិតជាមានកិត្តិយស និងក្តីសោមនស្សក្រៃលែងដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ **“កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៣”** ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គ លើកទី១ នាពេលនេះ។ នេះជាកិច្ចប្រជុំពេញអង្គចុងក្រោយរបស់យើងសម្រាប់អាណត្តិទី៦នេះ។

ជាមួយគ្នានេះ ខ្ញុំសូមគោរពថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅ ជូនចំពោះក្រសួង ស្ថាប័នពាក់ពន្ធ័ទាំងអស់ នៅក្នុងកិច្ចខិតខំប្រឹងប្រែង និងការសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការជំរុញ និងចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ដោយទទួលលទ្ធផលជាផ្លែផ្កា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា !**

ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គនេះ។

ក្នុងយន្តការឆ្ពោះទៅរកការពង្រឹងប្រព័ន្ធជាតិ និងភាពជាម្ចាស់ ក្នុងការឆ្លើយតបជាពហុវិស័យចំពោះការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាពនៅកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមវាយតម្លៃខ្ពស់ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការចេញប្រកាសលេខ ៥៥៨ សហវ.អហក ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំសិក្ខាសាលា និងកិច្ចប្រជុំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសលេខ ៥៥៩ សហវ.ប្រក ស្តីពីវិធាននិងនីតិវិធីចំណាយបេសកម្មនៅក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ ដែលបានជួយគាំទ្រគោលនយោបាយជាតិសម្រាប់ប្រើប្រាស់ថវិការដ្ឋនៅថ្នាក់ក្រោមជាតិ ឆ្លើយតបវិធានការ៦ចំណុចរបស់សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៩ ។

សមិទ្ធិផលរបស់ប្រទេសកម្ពុជាត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបាននូវអត្រាទទួលសេវាព្យាបាលខ្ពស់បំផុត និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។ គិតត្រឹម ខែធ្នូ ឆ្នាំ២០២២ អ្នកផ្ទុកមេរោគអេដស៍ ៦៥.៦៤៦នាក់ បានកំពុងទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដោយឥតគិតប្រាក់ពីមូលដ្ឋានសុខាភិបាលរបស់រដ្ឋ ត្រូវជា ៩៩% នៃអ្នកផ្ទុកមេរោគអេដស៍ បានដឹងពីស្ថានភាពដែលកំពុងទទួលការព្យាបាល ហើយ ៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ដែលទទួលការព្យាបាល ត្រូវបានពិនិត្យឃើញថា រកឃើញបន្ទុកមេរោគអេដស៍ទាបបំផុត (Viral load supression)។ ភាពរឹងមាំច្បាស់លាស់នៃការឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជា បានបញ្ជាក់អំពីសមត្ថភាពនៃការបញ្ចូលអ្នកផ្ទុកមេរោគអេដស៍ ឱ្យទៅទទួលសេវាព្យាបាលពេលបានធ្វើរោគវិនិច្ឆ័យរួច និងរក្សាទុកឱ្យនៅព្យាបាល ព្រមទាំងលទ្ធភាពបង្កើនប្រសិទ្ធភាពនៃការព្យាបាលជាអតិបរមា ដែលគេលែងឃើញ មេរោគនៅក្នុងខ្លួនអ្នកជំងឺ ជាបច្ច័យនាំឱ្យលែងមានការចម្លងមេរោគ (**Undetected = Untransmittable**)។

ជាមួយគ្នានេះដែរ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បាន និងកំពុងរៀបចំគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍ ឆ្នាំ២០២៣-២០២៨ តាមរយៈលិខិតលេខ៩២៧ សជណ ចុះថ្ងៃទីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាថ្មីមួយទៀត និងជាកត្តាមិនអាចខ្វះបាន ដើម្បីសម្រេចគោលដៅ

លុបបំបាត់មេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសការពង្រឹងប្រព័ន្ធជាតិ ( Country System ) ក្នុងការឆ្លើយតបជាពហុវិស័យ ចំពោះការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ឈានទៅសម្រេចឱ្យបានក្នុងពេលឆាប់ៗនូវចីរភាពនៃកម្មវិធីអេដស៍នៅកម្ពុជា។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីផ្តល់សាច់ប្រាក់ជូនប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩ ហើយក្នុងនោះ គ្រួសារផ្ទុកមេរោគអេដស៍ចំនួនប្រមាណជាង២.០០០គ្រួសារ ក៏ទទួលបានការឧបត្ថម្ភសាច់ប្រាក់ប្រចាំខែពីកម្មវិធីផងដែរ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមវាយតម្លៃខ្ពស់ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានជួយគាំទ្រគោលនយោបាយជាតិរបស់យើង ដោយបានដាក់ចេញ នូវនីតិវិធីជាតិ សម្រាប់ប្រើប្រាស់ថវិការដ្ឋនៅថ្នាក់ក្រោមជាតិ និងផ្តល់ថវិកាសម្រាប់ការងារអេដស៍ ដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ទោះជាក្នុងកម្រិតណាក៏ដោយ ដែលនេះជាកត្តាមិនអាចខ្វះបាន ដើម្បីសម្រេចគោលដៅលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!

ខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមគម្រោងផែនការសកម្មភាពឆ្នាំ២០២៣ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ យើងពិនិត្យមើលរួមគ្នានូវ វឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់រយៈពេល៦ខែដើមឆ្នាំ២០២៣ និងធ្វើការប្រមូល និងពិភាក្សាលើធាតុចូល និងអនុសាសន៍មួយចំនួនតាមរយៈការចូលរួមរបស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញាដែលមានវត្តមានក្នុងពេលនេះ។

តាមរបៀបវារៈកិច្ចប្រជុំ យើងនឹងមានបទបង្ហាញចំនួនពីរ រួមមាន ៖

- ទី១ បទបង្ហាញ ស្តីពីវឌ្ឍនភាពនៃការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២២ បង្ហាញជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

- ទី២ បទបង្ហាញ ស្តីពីការរៀបចំសេចក្តីព្រៀងគោលនយោបាយជាតិ បញ្ចប់អេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបនឹងជំងឺអេដស៍ បង្ហាញជូនដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

បន្ទាប់មកយើងនឹងមានការពិភាក្សារួមគ្នា និងដាក់ចេញនូវសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**!

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមទាញអារម្មណ៍កិច្ចប្រជុំពេញអង្គថា យើងបាន និងកំពុងតែធ្វើដំណើររួមគ្នាប្រកបដោយទស្សនវិស័យច្បាស់លាស់ក្នុងក្តីសង្ឃឹមពិតប្រាកដ ឆ្ពោះទៅរកការលុបបំបាត់ជំងឺអេដស៍ក្នុងពេលដ៏ខ្លីខាងមុខ ។ យើងមានក្តីសង្ឃឹម ដោយសារតែយើងទទួលបាន នូវការប្តេជ្ញាចិត្ត និងការគាំទ្រនយោបាយដ៏រឹងមាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ យើងនឹងកសាងបាននូវបីរភាព នៃការឆ្លើយតបជាពហុវិស័យ ទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។ ទាំងអស់គ្នាយើងត្រូវខិតខំបង្កើតឱ្យបាននូវស្ថាប័នដឹកនាំគ្រប់គ្រង និងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស យើងត្រូវមានផែនការយុទ្ធសាស្ត្រជាតិតែមួយ មានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**!

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ដែលនឹងផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តអនុវត្តការងារឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងពេលខាងមុខ ឱ្យស្របទៅតាមអនុសាសន៍ និងសេចក្តីសម្រេចចិត្ត ដែលនឹងផ្តល់ជូន និងដាក់ចេញដើម្បីអនុម័តក្នុងកិច្ចប្រជុំពេញអង្គនាពេលបន្តិចទៀតនេះ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ការងារពីបណ្តាសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំនាពេលនេះតែប៉ុណ្ណេះ។

ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៣** " ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!